**ស្ថានទូតអូស្ត្រាលី**

**ភ្នំពេញ**


# សេចក្តីប្រកាសព័ត៌មាន

## ការប្រារព្ធពិធីខួបមួយទស្សវត្សនៃកិច្ចសហប្រតិបត្តិការស្រាវជ្រាវនៅអង្គរវត្ត

សាកលវិទ្យាល័យស៊ីដនី (University of Sydney) ប្រារព្ធខួបអនុស្សាវរីយ៍ដប់ឆ្នាំនៃកិច្ចសហប្រត្តិបត្តការស្រាវជ្រាវប្រកបដោយជោគជ័យនៅអង្គរវត្ត ដោយរៀបចំពិធីអាហារពេលល្ងាចមួយដែលនឹងប្រព្រឹត្តទៅនៅពេលល្ងា ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩ នៅប្រាសាទបាយ័ន អង្គរវត្ត ក្រោមព្រះរាជ្យអធិបតិភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

ពិធីអាហារពេលល្ងាចនេះ ត្រូវបានសហការរៀបចំដោយ លោកជំទាវ **ម៉ាហ្គារ៉េត អាដាមសុន** (H.E. Margaret Adamson) ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជា និងលោកបណ្ឌិត **ម៉ៃខល ស្ពែន** (Dr. Michael Spence) សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យស៊ីដនី (University of Sydney) ។ ព្រះអង្គម្ចាស់ **សម្តេច នរោត្តម សិរីវុឌ្ឍ** នឹងយាងជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះមហាក្សត្រ ។ ឯកឧត្តម **សុខ អាន** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា នឹងអញ្ជើញជាភ្ញៀវកិត្តិយសនៅក្នុងពិធីនេះផងដែរ និងមានការអមតំណើរដោយមន្ត្រីជាន់ខ្ពស់ចំនួនប្រហែល១០០នាក់ មកពីអាជ្ញាធរអប្សរា អង្គការយូណេស្កូ អ្នកប្រាជ្ញកម្ពុជា និងអន្តរជាតិដ៏ឧត្តុងឧត្តម ក៏ដូចជាអ្នកតំណាងការទូត ដែលចូលរួមប្រជុំពេញអង្គនៃគណៈកម្មការសម្របសម្រួលអន្តរជាតិ នៅខេត្តសៀមរាប ។

ពិធីអាហារពេលល្ងាចនេះ នឹងបង្ហាញអោយឃើញនូវអាហារអូស្ត្រាលីដ៏ល្អបំផុត ព្រមទាំងភេជ្ជៈស្រាដ៏ល្បីទៃទៀត ដែលរៀបចំដោយមេចុងភៅអូស្ត្រាលីឯកទេសអាហារនិងស្រា គឺលោក **ដន ហានសី** (Don Hancey) ។ លោក ស្ទូអាត វ៉ៃល ដេវិដ ហ្គីលមួរ ដាន់ណៀល ស្សាប និងបុគ្គលិក ព្រមទាំងនិស្សិតមកពីសាលាទេសចរណ៍ និងទទួលសំណាក់អាស្រ័យ (Paul Du Brule School of Hospitality and Tourism) នៅខេត្តសៀមរាប និងជួយដល់លោក ហានសី ក្នុងកិច្ចការម្ហូបអាហារនេះ ។

សាកលវិទ្យាល័យស៊ីដនី (University of Sydney) គឺជាសាកលវិទ្យាល័យនាំមុខគេមួយនៅលើពិភពលោកក្នុងការស្រាវជ្រាវផ្នែកបុរាណវិទ្យាប្រកបដោយគំនិតឆ្នៃប្រឌិត និងវិធីសាស្រ្តថ្មីនៅប្រាសាទអង្គរវត្តនៃប្រទេសកម្ពុជា ។ កម្មវិធីស្រាវជ្រាវចំរុះរួមគ្នាជាលក្ខណៈអន្តរជាតិក្រោមការដឹកនាំរបស់ខ្លួនបានបង្ហាញពិភពលោកអោយឃើញនូវវិសាលភាពយ៉ាងពិតប្រាកដ និងអនុភាពនៃអរិយធម៌ខ្មែរដ៏រីកចំរើននាយុគសម័យនោះ ។

នាពេលកន្លងមកនេះ សាកលវិទ្យាល័យស៊ីដនី (University of Sydney) បានទទួលមូនិធិថ្មីចំនួន ១.២៥ លានដុល្លាអូស្ត្រាលី ពីក្រុមប្រឹក្សាស្រាវជ្រាវអូស្ត្រាលីសំរាប់ឆ្នាំ២០១០-២០១៥ ដើម្បីអនុវត្តគំរោងស្រាវជ្រាវពីរនៅក្នុងប្រទេសកម្ពុជា ។ គំរោងទី១ គឺការបន្តគំរោងមហាអង្គរដែលសិក្សាអំពីសេដ្ឋកិច្ច និងការបោះបង់ចោលអង្គរវត្ត ក្នុងភាពជាដៃគូររបស់អាជ្ញាធរអប្សរា ។ គំរោងទី២ គឺការសិក្សាលើការផ្លាស់ប្តូបរិស្ថានសម័យបុរាណកាលពី ៨00.000 ឆ្នាំមុន នៅប៉ែកឥស្សាននៃប្រទេសកម្ពុជា ។

សាកលវិទ្យាល័យស៊ីដនី (University of Sydney) មានកម្មវិធីយ៉ាងសកម្មមួយក្នុងកិច្ចសហប្រត្តិបត្តិការលើវិស័យមនុស្សធម៌ វិទ្យាសាស្រ្ត ការអប់រំ សុខភាព និងបេតិកភណ្ឌ នៅក្នុងប្រទេសកម្ពុជា។

ព័តមានបន្ថែមស្តីពីគំរោងមហាអង្គរ សូមទស្សនាគេហទំព័រ:
http://acl.arts.usyd.edu.au/angkor/gap

**ទំនាក់ទំនងសារពិតមានះ**

*លោកស្រី* ***ហ្វីយ៉ូណា ខូឆូ (Ms Fiona Cochaud), DHOM, 023 213 470***

**ស្ថានទូតអូស្រ្តាលី រាជធានីភ្នំពេញ**

ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៩